# របាយការណ៍ប្រចាំខែឧសភា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ

I. **ស្ថានភាពការងាររបស់មន្ទីរ ÷**

1. **ការិយាល័យ រដ្ឋបាល និងកិច្ចការទូទៅ ÷**

❖ ស្ថានភាពបុគ្គលិកមន្ត្រីរាជការក្នុងមន្ទីរ

ការងារគ្រប់គ្រងនិងដឹកនាំមន្ទីរមានថ្នាក់ដឹកនាំចំនួន ៣ រូប (ប្រធានមន្ទីរ និងអនុប្រធានមន្ទីរ ០២ រូប) និងមានការិយាល័យជំនាញចំនួន ១០ ការិយាល័យ ÷

១- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ
២- ការិយាល័យផែនការ-ស្ថិតិ
៣- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ
៤- ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ
៥- ការិយាល័យអភិវឌ្ឍន៍សហគមន៍
៦- ការិយាល័យផ្គត់ផ្គង់ទឹកជនបទ
៧- ការិយាល័យថែទាំសុខភាពជនបទ
៨- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
៩- ការិយាល័យផ្លូវជនបទ
១០- ការិយាល័យអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងមានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកចំនួន ០៧ និងក្រុងចំនួន ០១។

1.1. **ចំនួនមន្ត្រីរាជការ**

- សរុប ÷ ២១នាក់
- ប្រុស ÷ ១៨នាក់
- ស្រី ÷ ០៤នាក់
- ចំនួនប្រពន្ធមន្ត្រីរាជការ ÷ ១២ នាក់
- ចំនួនកូន ÷ ២២ នាក់
- អវត្តមាន ÷ គ្មាន
- ចំនួនមន្ត្រីរាជការដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ÷ គ្មាន
- ចំនួនមន្ត្រីរាជការផ្ទេរចូល ÷ គ្មាន
- ចំនួនមន្ត្រីរាជការផ្ទេរចេញ ÷ គ្មាន
- ចំនួនមន្ត្រីរាជការក្រោបខ័ណ្ឌថ្មី ÷ គ្មាន

- ចំនួនមន្ត្រីរាជការបានតំឡើងប្រាក់បំណាច់មុខងារ ÷ គ្មាន
- ចំនួនមន្ត្រីរាជការបានតំឡើងឋានៈ ÷ គ្មាន
- ចំនួនមន្ត្រីរាជការចូលនិវត្តន៍ ÷ គ្មាន
- ចំនួនបុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកបណ្តែត ÷ គ្មាន
- ចំនួនមន្ត្រីរាជការដែលទៅបំពេញបេសកកម្មនៅបរទេស ÷ គ្មាន
- ចំនួនមន្ត្រីរាជការសហការជាមួយកម្មវិធី និងជាដៃគូអង្គការនានា ÷០៦នាក់

| ល.រ | នាម និងគោត្តនាម | ភេទ | មុខងារ | សហការជាមួយអង្គការ ឬកម្មវិធី |
|---|---|---|---|---|
| ១ | សេង សារី | ប | ប្រធានមន្ទីរ | -គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ២ | ម៉ប់ ធីរិត | ប | អនុប្រធានមន្ទីរ | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៣ | ឈុន ប៊ុនថេង | ប | ប្រធានការិយាល័យ | គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម(ADB) |
| ៤ | ញាណ គង់ | ប | មន្ត្រី | - គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទាន បន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៥ | ឃិត សុធារ៉ា | ប | មន្ត្រី | គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម(ADB) |
| ៦ | ឆាយ សុវណ្ណា | ស | មន្ត្រី | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |

1.2. **ការងារលិខិតចេញ-ចូល**

បានធ្វើចរាចរលិខិតស្នាម ក្នុងនោះមាន÷

- មន្ទីរបានចេញលិខិតបេសកកម្មចំនួន ១១ច្បាប់
- មន្ទីរបានចេញលិខិតទៅស្ថាប័ននានា និងក្នុងមន្ទីរចំនួន ១០ច្បាប់
- បានទទួលលិខិតចូលពីគ្រប់ស្ថាប័ននានាចំនួន ២០ច្បាប់
- លិខិតផ្សេងៗចំនួន ០១ច្បាប់។

1.3. **ការងាររដ្ឋបាល និងបុគ្គលិក**

- បានរៀបលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកផ្សេងៗជូនមន្ត្រីរាជការចេញដោយមន្ទីរចំនួន ÷ ១ ច្បាប់
- បានចូលរួមប្រជុំក្រៅខេត្តចំនួន ÷០១លើក
- បានចូលរួមប្រជុំក្នុងខេត្តចំនួន ÷១២លើក

– បានចូលរួមប្រជុំផ្ទៃក្នុងមន្ទីរចំនួន ÷០៣លើក

1.4. **ការងារបៀវត្ស និងពលកម្ម**

– បានរៀបចំលិខិតផ្តាច់បៀវត្សមន្ត្រីផ្ទេរចេញ
– បានរៀបចំបើកប្រាក់បៀវត្សប្រចាំខែឧសភា ឆ្នាំ២០១៥
– បានរៀបចំប្រាកបៀវត្សជូនមន្ត្រីជាប់កិច្ចសន្យា។

1.5. **ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ**

\+ **ប្រភពថវិការដ្ឋផ្តល់**

- **ថវិកាអនុម័តឆ្នាំ២០១៥ = ៤៤០.៥០០.០០០រ០០**
  – ប្រាក់ជំពូក ៦០ = ៧០.០០០.០០០រ០០
  – ប្រាក់ជំពូក ៦១ = ១៧១.៥០០.០០០រ០០
  – ប្រាក់ជំពូក ៦៤ = ១៩៨.០០០.០០០រ០០
  – ប្រាក់ជំពូក ៦៣ = ១.០០០.០០០រ០០
- **ថវិកាចំណាយសម្រាប់ខែឧសភា ឆ្នាំ២០១៥ = ១៦,១០៣,០៤០.០០៛**
  – ប្រាក់ជំពូក ៦១ = ០០រ០០
  – ប្រាក់ជំពូក ៦៤ = ១៦,១០៣,០៤០.០០៛
  – ប្រាក់ជំពូក ៦៣ = ០០រ០០

– បើកប្រាក់បៀវត្សខែ ឧសភាឆ្នាំ ២០១៥ ជូនមន្ត្រីរាជការមន្ទីរ
– ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើឯកសារលទ្ធកម្ម នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត
– សំណើសុំធ្វើលទ្ធកម្មលើសម្ភារៈការិយាល័យ និងប្រេងឥន្ធនៈ សម្រាប់ឆ្នាំ ២០១៥ ទៅអង្គភាពលទ្ធកម្ម សាលាខេត្ត
– ធ្វើផែនយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០១៦ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
– ថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ចូលរួមប្រជុំផ្សព្វផ្សាយសារាចរ ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ ថវិកាឆ្នាំ២០១៦ នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការចូលរួមពីមន្ទីរពាក់ព័ន្ធ សម្របសម្រួលមន្ត្រីដោយមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

2. **ការងារផែនការ និងស្ថិតិ** ÷

– គ្មានសកម្មភាព

3. **ការងារអធិការកិច្ច និង សវនកម្ម**÷

– គ្មានសកម្មភាព

4. **ការងារទំនាក់ទំនងសាធារណៈ**:

– គ្មានសកម្មភាព

II. **សកម្មភាពការងារតាមវិស័យ ÷**

1. **សកម្មភាពផ្លូវជនបទ**

   – ថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០១៥ ចូលរួមប្រជុំណែនាំស្ដីពីការអនុវត្តគម្រោងមូលនិធិឃុំ-សង្កាត់ ឆ្នាំ ២០១៥ នៅ សាលប្រជុំសាលាខេត្ត ដោយមានការចូលរួមពីទីប្រឹក្សាគម្រោង រដ្ឋបាលសាលាខេត្ត មន្ត្រីបច្ចេកទេស មន្ទីរ ពាក់ព័ន្ធ ក្រុមប្រឹក្សាឃុំ-សង្កាត់។ល។

2. **សកម្មភាពការងារចុះស្រង់ទិន្នន័យ**

   – ថ្ងៃទី ០៤-០៦ ខែឧសភា ឆ្នាំ២០១៥ ចុះស្រង់បញ្ជីសារពើភ័ណ្ឌ និងទិន្នន័យផ្លូវជនបទ នៅស្រុកជាំក្សាន្ត បាន ចំនួន ២៤ គីឡូម៉ែត្រ ជាផ្លូវប្រភេទលេខ៤។

3. **ការងារធ្វើបច្ចុប្បន្នភាព**

   – គ្មានសកម្មភាព។

4. **ការងារផ្គត់ផ្គង់ទឹកជនបទ**

   – នៅថ្ងៃទី ២៧ដល់ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៥៖ បានចុះជួសជុលអណ្ដូងស្នប់បានចំនួន ៥ណ្ដូង(ក្បាលខ្មៅចំនួន ១)នៅភូមិ អន្លង់ស្វាយ និងភូមិក្រាំងដូង ឃុំព្រះឃ្លាំង និងភូមិបុសធំ ឃុំប្រមេរុ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ
   – នៅថ្ងៃទី ៤ ដល់ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៥÷ បានចុះតបណ្ដាញប្រព័ន្ធចែកចាយទឹកភូមិកើ្ត និងភូមិសំរិតបាន ៧៥%នៃចំនួនសរុប(ទាំងជីក និងកប់ទុយោ)។

5. **ការងារថែទាំសុខភាពជនបទ**

   – នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៥ នៅសាលប្រជុំមន្ទីរបានបើកកិច្ចប្រជុំណែនាំក្នុងការរៀបចំធ្វើសិក្ខាសាលាពិគ្រោះយោបល់ស្ដីពីកសាងផែនការសកម្មភាពលើវិស័យផ្គត់ផ្គង់ទឹកស្អាត និង អនាម័យជនបទ ឆ្នាំ២០១៤-២០១៨សម្រាប់ខេត្តក្រោមការសម្របសម្រួលពីលោកបណ្ឌិត ដោក ដូម៉ា មន្ត្រីសម្របសម្រួលខេត្ត។ អញ្ជើញចូលរួម ÷ លោក លោកស្រីជាជនបង្គោលទឹកស្អាត និងអនាម័យប្រចាំមន្ទីរទាំង៣រូប។

6. **ការងារបណ្ដុះបណ្ដាល និង ស្រាវជ្រាវ ÷**

   – ថ្ងៃទី ២០ ខែ មេសា ដល់ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០១៥ ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីជំនាញលទ្ធកម្ម សាធារណៈ សម្របសម្រួលដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ÷
     - ផែនការថវិកា ÷ គំរូផែនការលម្អិត តារាងផែនការសរុប តារាងផែនការកែតម្រូវលម្អិត គំរូរបាយការណ៍លម្អិត គំរូរបាយការណ៍
     - យន្តការគ្រប់គ្រងលទ្ធកម្ម ÷ សេចក្ដីផ្ដើម ស្ថាប័នគ្រប់គ្រងលទ្ធកម្ម ស្ថាប័នអនុវត្តលទ្ធកម្ម

- លទ្ធកម្មទំនិញ÷ ដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ
- លទ្ធកម្មសេវាទីប្រឹក្សា
- លទ្ធកម្មសំណង់ ÷ ដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ

7. **ការងារអភិវឌ្ឍន៍សហគមន៍÷**

– គ្មានសកម្មភាព។

8. **ការងារសេដ្ឋកិច្ចជនបទ÷**

– គ្មានសកម្មភាព។

9. **ការងារជនជាតិដើមភាគតិច÷**

– នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៥ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីគោលនយោបាយអភិវឌ្ឍន៍ជនជាតិដើមភាគតិច វាយតម្លៃស្វ័យអត្តសញ្ញាណជនជាតិដើមភាគតិច និងនិតិវិធីនៃការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច នៅសាលាប្រជុំជាន់ទី៣ អាគាររដ្ឋបាលសាលាខេត្ត។ ក្រោមអធិបតីភាព ឯកឧត្តម ហាប់ អូម៉ាលី អនុរដ្ឋលេខាធិការ តំណាងឯកឧត្តមរដ្ឋមន្ត្រី និង ឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាល នៃគណៈអភិបាលខេត្ត និងមានការចូលរួមពីតំណាងមន្ទីរ អង្គភាពជុំវិញខេត្ត អាជ្ញាធរស្រុក ឃុំ អង្គការដៃគូពាក់ព័ន្ធ សរុបប្រមាណ ៨៥នាក់។ សិក្ខាសាលានេះរៀបចំដោយនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិដើមភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ គាំទ្រថវិកាដោយអង្គការ ILO។

10. **ការងារយេនឌ័រ÷**

– គ្មានសកម្មភាព។

11. **ការងារ** NGOs÷

– នៅថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៥ នៅភោជនីយ៍ដ្ឋានរស្មីច័ន្ទពេញវង់II ក្រុងព្រះវិហារ ថ្នាក់ដឹកនាំមន្ទីរ ០២រូប បានចូលរួមជាវាគ្មិនក្នុងកម្មវិធីមហោស្រពយុវជន ក្រោមប្រធានបទយុទ្ធនាការបញ្ឈប់ការកង្វះអាហា រូបត្ថម្ភរបស់កុមារដោយមានការចូលរួមពីក្រុមយុវជនតាមបណ្តាស្រុកគោលដៅទាំង៧សរុបប្រមាណ១,៥៨០នាក់កម្មវិធីនេះរៀបចំ និងគាំទ្រដោយអង្គការទស្សនៈពិភពលោកប្រចាំខេត្ត។

12. **គម្រោង / កម្មវិធី ÷**

12.1. **គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញទានបន្ថែម** (ADB)

– ថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៥ ចុះត្រួតពិនិត្យក្រាលក្រួសក្រហម ០១ខ្សែ ប្រវែង ៨,៣២២ម៉ែត្រ និងសំណង់ សិល្បៈការចំនួន ១១កន្លែង ក្នុងនោះលូប្រអប់ចំនួន ០២កន្លែង លូទ្រាប ០១កន្លែង លូភ្លោះ០៣កន្លែង និងលូ ទោលចំនួន០៥កន្លែង នៅឃុំពោធិ ស្រុកត្បែង

មានជ័យ ។ លទ្ធផលសម្រេចបានក្រុមហ៊ុនបានក្រាលគ្រួសក្រហមបានប្រវែង ៨ ៣២២ម ស្មើនឹង ១០០% សាងសង់លូប្រអប់ចំនួន ០១កន្លែង (៣មx៣មx៦ម) អនុវត្តបាន ៩០%។

12.2. **កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ នៅតាមសាលារៀន និងសហគមន៍** (**គាំទ្រថវិកាដោយ** UNICEF)

- ថ្ងៃទី ២៣-២៥ ខែមេសា ឆ្នាំ ២០១៥ ក្រុមការងារទឹកស្អាត និងអនាម័យរបស់មន្ទីរ បានចុះធ្វើយុទ្ធនាការ ជម្រុញបំផុស តាមរយៈបញ្ចាំងវីដេអូរឈុតខ្លីៗ ស្តីពីសារលើកកម្ពស់ក្នុងការប្រើប្រាស់ទឹកស្អាត និងអនាម័យ ជនបទដល់ប្រជាពលរដ្ឋមកពីភូមិត្រាវគៀត ភូមិស្ទឹងសែនមនោរម្យ ភូមិថ្មល់បែក និងភូមិពង្រ នៃឃុំថ្មី ស្រុក គូលែន ដោយមានចូលរួមសរុប ៤១២នាក់ ក្នុងនោះស្ត្រី ៣០៣នាក់ កុមារ ១៤៩នាក់។

12.3. **គម្រោងអភិវឌ្ឍន៍តាមបណ្តោយព្រំដែនខាងលិច ខាងជើង÷**

- ព្រឹកថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០១៥ នៅភូមិមរតកតេជោ ឃុំរំដោះស្រែ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ **ឯកឧត្តម ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីសម្រប សម្រួលរៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើងនៃព្រះរាជា ណាចក្រកម្ពុជា និង ឯកឧត្តម គន់ គីម អគ្គមេបញ្ជាការរង និងជានាយសេនាធិការចម្រុះនៃកងយោធពល ខេមរៈភូមិន្ទ ព្រមទាំង ឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាលខេត្តព្រះវិហារ អញ្ជើញជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធី បើកការដ្ឋានសាងសង់ផ្លូវក្រាលគ្រួសក្រហម ០៣ខ្សែ ប្រវែង ៤,៦០០គ.ម អណ្តូងស្នប់ក្បាល Afrideve ចំនួន ១០ និងស្រះសហគមន៍ចំនួន ០១ ជូនដល់គ្រួសារកងទ័ពរស់នៅតាមបណ្តោយព្រំដែនខ្មែរ-ថៃស្ថិតក្នុងភូមិសា ស្ត្រស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ឆ្លៀតក្នុងឱកាសនេះដែរ ឯកឧត្តមបានធ្វើការសំណេះសំណាលជាមួយ គ្រួសារកងទ័ពជាង ៤០០គ្រួសារ និងកងកម្លាំងប្រដាប់អាវុធចំនួន ៤០០នាក់ ចំណុះអោយកងពលធំលេខ ៣៕